**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ធនាគារជាតិនៃកម្ពុជាចេញគោលនយោបាយ១០ចំណុចគាំទ្រការងើបឡើងកំណើនសេដ្ឋកិច្ចឆ្នាំ២០២២
- ឧស្សាហកម្មធនាគាររបស់ប្រទេសកម្ពុជាមានកំណើន ផ.ស.ស ៣% និងប្រាក់បញ្ញើ ៣៨,៥ប៊ីលានដុល្លារ កាល ពីឆ្នាំមុន បើទោះបីជាជំងឺកូវីដ-១៩កំពុងរាតត្បាតក៏ដោយ
- ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ល្អបំផុតសម្រាប់ការចំណាយប្រតិបត្តិការផលិតកម្មទាបបំផុតក្នុងចំណោម ប្រទេសចំនួនប្រាំបួននៅអាស៊ី
- ការលើកលែងពន្ធលើមុខទំនិញមួយចំនួនពីរដ្ឋជាការរួមចំណែកជួយរក្សាតម្លៃទំនិញលើទីផ្សារ
- កម្ពុជាត្រូវវាយតម្លៃលើកដំបូងថាបានបំពេញលក្ខខណ្ឌចាំបាច់បី ដើម្បីចេញពីប្រទេសអភិវឌ្ឍតិចតួច
- រដ្ឋាភិបាលម៉ាឡេស៊ី ត្រៀមចំណាយថវិកាសរុប៦៨០លានរីងហ្គីត ដើម្បីធានាស្ថិរភាពតម្លៃទំនិញចាំបាច់
- ធនាគារជាតិឥណ្ឌូនេស៊ី នឹងរក្សាអត្រាការប្រាក់រហូតដល់ឆមាសទី២ នៃឆ្នាំ២០២២ បើទោះបីជាធនាគារ កណ្តាលអាមេរិក ដំឡើងអត្រាការប្រាក់ដើម្បីទប់ទល់នឹងការកើនឡើងអតិផរណាក៏ដោយ
- ក្រុមហ៊ុនជប៉ុន៧០%នៅបន្ត និងពង្រីកធុរកិច្ចនៅមីយ៉ាន់ម៉ា ក្រោយពេលមានរដ្ឋប្រហារយោធា
- ប្រធានធនាគារពិភពលោកប្រាប់ឱ្យប្រទេសចិន ជួយបន្ធូរបន្ថយបំណុលសម្រាប់ប្រទេសក្រីក្រ
- សេដ្ឋកិច្ចចិន កើនឡើង ៨.១% ក្នុងឆ្នាំ២០២១
- សន្ទស្សន៍ប្រេងឆៅពិភពលោក កើនឡើងដល់កម្រិតខ្ពស់ជាង ៧ឆ្នាំចុងក្រោយ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៤ ខែមករា ឆ្នាំ២០២២ លេខ ៖ ១០៣

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារជាតិនៃកម្ពុជាដាក់ចេញគោលនយោបាយ១០ ចំណុច ដើម្បីគាំទ្រការងើបឡើងនៃកំណើនសេដ្ឋកិច្ចឆ្នាំ ២០២២



*(រូបភាព ៖www.nbc.gov.kh,ធនាគារជាតិនៃកម្ពុជា)*

ឆ្នាំ២០២២ អត្រាកំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានគេព្យាករថានឹងទាបជាងការរំពឹងទុក ដោយសារការគំរាមកំហែងដោយមេរោគបំប្លែងថ្មី អូមីក្រុង។ សម្រាប់ប្រទេសកម្ពុជាក៏កំពុងប្រឈមនឹងហានិភ័យនៃការរាតត្បាតកូវីដ១៩ដូចគ្នា ហើយការប្រឈមនេះ ក៏អាចនឹងនាំទៅរកការដាក់ចេញវិធានការការពារតឹងរ៉ឹង ដែលអាចប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកផងដែរ។ ដើម្បីគាំទ្រដល់ការងើបឡើងនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធនាគារជាតិបានសម្រេចដាក់ចេញនូវគោលនយោបាយចម្បងៗចំនួន១០ចំណុច រួមមាន៖ទី១.ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់,ទី២.ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល,ទី៣.ការអនុវត្តវិធានការគាំទ្រចំគោលដៅ,ទី៤.ការលើកកម្ពស់បរិយាបន្ន និងចំណេះដឹងហិរញ្ញវត្ថុ,ទី៥.សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំងអស់ ត្រូវបន្តគាំទ្រការរីកលូតលាស់សេដ្ឋកិច្ចក្នុងតំបន់,ទី៦.ការទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ, ទី៧.ការពង្រឹងផែនការនិរន្តរភាពអាជីវកម្ម និងផែនការអនុវត្តជាយថាហេតុ។ ទី៨. ការពង្រឹងប្រសិទ្ធភាពនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម, ទី៩.ការរួមចំណែកក្នុងការកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ និងទី១០.ក្នុងនាមកម្ពុជាជាប្រធានអាស៊ាននៅឆ្នាំ២០២២នេះ ធនាគារជាតិនៃកម្ពុជានឹងរួមចំណែកពង្រឹងសមាហរណកម្មហិរញ្ញវត្ថុ និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ តាមរយៈការធ្វើសេរីភាវូបនីយកម្មសេវាធនាគារ សមាហរណកម្មប្រព័ន្ធទូទាត់ ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុតំបន់ និងយន្តការជួយផ្តល់ហិរញ្ញប្បទានសម្រាប់បង្ការ និងដោះស្រាយវិបត្តិ។ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាបានលើកឡើងថា ការគ្រប់គ្រងបានលើការរាលដាលជំងឺកូវីដ-១៩ និងការបន្តបើកដំណើរការសេដ្ឋកិច្ច ពិតជានឹងជំរុញសកម្មភាពសេដ្ឋកិច្ចដូចជា ពាណិជ្ជកម្ម ការវិនិយោគ ការដឹកជញ្ជូន និងទូរគមនាគមន៍ និងទេសចរណ៍ក្នុងស្រុក។ ក្នុងនោះ វិស័យកសិកម្មរំពឹងថា នឹងបន្តមានកំណើនល្អដែលគាំទ្រដោយគោលនយោបាយគាំពាររបស់រាជរដ្ឋាភិបាល និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងតំបន់ និងទ្វេភាគី។ ធនាគារជាតិនៃកម្ពុជា នៅតែមានសុទិដ្ឋិនិយមចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា ដោយរំពឹងថា នៅឆ្នាំ២០២២នេះ សេដ្ឋកិច្ចកម្ពុជា នឹងសម្រេចបានកំណើន៥%។ *ដោយ ម៉ែន ខែមរៈ ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១៧ខែមករាឆ្នាំ២០២២។*

## កម្ពុជារំពឹងការនាំចេញអង្ករ៨០ម៉ឺនតោនឆ្នាំ២០២២



*ដោយ ខេមបូណូមីស(អង្ករបស់កម្ពុជា)*

នៅក្នុងរយៈពេល១ឆ្នាំ ឆ្នាំ២០២១ កម្ពុជា បាននាំចេញកសិផលទៅកាន់ ៦៨ប្រទេស ក្នុងបរិមាណជិត ៨លានតោន បានកើនឡើងជាង ៦៣% បើប្រៀបនឹងឆ្នាំ២០២០។ ប៉ុន្តែក្នុងនោះ ការនាំចេញអង្ករសម្រេចបានតែប្រមាណ៦១ម៉ឺនតោនប៉ុណ្ណោះ ថយចុះ១០% ធៀបនឹងឆ្នាំ២០២០។

ប្រធានសហព័ន្ធស្រូវ-អង្ករកម្ពុជា បានអះអាងថា ការខ្វះនូវមធ្យោបាយដឹកជញ្ជូន គឺជាឧបសគ្គដែលធ្វើឱ្យការនាំចេញអង្ករនៅឆ្នាំ២០២១ ថយចុះ ហើយរហូតពេលនេះ ក៏មិនទាន់អាចដោះស្រាយនៅឡើយ។ បើកម្ពុជា នៅតែមិនអាចដោះស្រាយនូវបញ្ហានេះទេ ការនាំចេញអង្ករនៅឆ្នាំ២០២២ នឹងបន្តរងផលប៉ះពាល់ និងបន្តការកកស្ទះដដែល។ ប្រសិនណា កម្ពុជា អាចដោះស្រាយបាន នៅឆ្នាំ២០២២នេះ អាចនឹងនាំចេញអង្ករប្រមាណ៨០ម៉ឺនតោន។ ស្ថិតក្នុងស្ថានភាពដែលពិភពលោកកំពុងជួបការរាតត្បាតជំងឺកូវីដ-១៩ តម្រូវការអង្ករមានការកើនឡើង តែដោយសារកម្ពុជា ខ្វះខាតនូវមធ្យាបាយដឹកជញ្ជូន ពិសេសការដឹកជញ្ជូនទៅកាន់ទីផ្សារឆ្ងាយៗ ដូចជា សហគមន៍អឺរ៉ុប អូស្ត្រាលី និងប្រទេសអាហ្វ្រិក ជាដើម ដែលធ្វើឱ្យទីផ្សារងាកទៅបញ្ជាទិញអង្ករពីប្រទេសដទៃវិញ។ គួរបញ្ជាក់ដែរថា បើគ្មានអ្វីប្រែប្រួលទេ សភាពាណិជ្ជកម្មសហភាពអឺរ៉ុប នឹងលើកលែងការយកពន្ធលើអង្ករនាំចូលគ្រប់ប្រភេទពីកម្ពុជាឡើងវិញហើយនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ខាងមុខនេះតទៅ បន្ទាប់ពីអឺរ៉ុបបានកំណត់យកពន្ធអស់រយៈពេលប្រមាណ៣ឆ្នាំកន្លងមកនេះ។ នៅពេលនោះ កម្ពុជានឹងអាចក្ដោបក្ដាប់ទីផ្សារអឺរ៉ុបមកវិញបាន៤០%នៃការនាំចេញអង្ករសរុប៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។*

## វិស័យអាកាសចរណ៍កម្ពុជាចាប់ផ្ដើមមានសន្ទុះងើបឡើង ទោះកំពុងប្រឈមនឹងអូមីក្រុង




*ដោយ ខេមបូណូមីស(ព្រលានយន្តហោះអន្តរជាតិភ្នំពេញ)*

វិស័យអាកាសចរណ៍របស់កម្ពុជា នៅមួយរយៈចុងក្រោយនេះ ហាក់ងើបឡើងវិញគួរឱ្យកត់សម្គាល់ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា មានការបន្ធូរបន្ថយការធ្វើចត្តាឡីស័កសម្រាប់អ្នកដំណើរ។ បច្ចុប្បន្ន មានអ្នកដំណើរប្រមាណ ៧រយនាក់ ទៅ១ពាន់នាក់ ក្នុងមួយថ្ងៃ បានចូលមកប្រទេសកម្ពុជា។ អ្នកដំណើរទាំងនោះ រួមមានភ្ញៀវទេសចរ និងអ្នកវិនិយោគបរទេស រួមទាំងការធ្វើដំណើររបស់ពលរដ្ឋកម្ពុជា ផងដែរ។ បើទោះបីជា ចំនួនអ្នកដំណើរបរទេសចូលមកកម្ពុជាមានការកើនឡើងក៏ពិតមែនប៉ុន្តែអ្នកជំនាញនៅតែបារម្ភដដែល ដោយសារតែវីរុសបំប្លែងថ្មីប្រភេទអូមីក្រុង កំពុងបន្តរីករាលដាលនៅឡើយ។

ទាក់ទិននឹងតម្លៃសំបុត្រយន្តហោះ រវាងកម្ពុជា និង ប្រទេសចិន ដែលឡើងថ្លៃកប់ពពកនោះ គឺនៅតែមាន តម្លៃថ្លៃដដែល ព្រោះប្រទេសចិន នៅតែបន្តនូវវិធានការ គ្មានកូវីដ១៩ និងបន្តរឹតត្បិតជើងហោះហើរចេញ-ចូល ប្រទេសរបស់ខ្លួនដដែល។ រហូតមកបច្ចុប្បន្ន តម្លៃ សំបុត្រកម្ពុជា-ចិន មានតម្លៃប្រមាណ ៥ពាន់ដុល្លារ ទៅ ៥ពាន់៥រយដុល្លារ សម្រាប់១ជើង៕ *ដោយ ម៉ែន ខែមរៈ* *ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២។*

## ឆ្នាំ២០២១ ឧស្សាហកម្មធនាគាររបស់ប្រទេសកម្ពុជា មានកំណើន ផ.ស.ស ៣% និងប្រាក់បញ្ញើ ៣៨,៥ប៊ីលាន ដុល្លារ បើទោះបីជាជំងឺកូវីដ-១៩កំពុងរាតត្បាត



*ប្រភព៖khmertimes, 2021*

យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា (NBC) បានបង្ហាញថា៖ឧស្សាហកម្មធនាគាររបស់កម្ពុជាមាន កំណើនដ៏រឹងមាំនៃប្រាក់កម្ចីនិងប្រាក់បញ្ញើនៅឆ្នាំ ២០២១ បើទោះបីជាផលប៉ះពាល់នៃការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏ដោយ។

សម្រាប់ប្រាក់កម្ចីបានកើនឡើង ២១,២%ធៀបនឹងឆ្នាំមុន មានរហូតដល់ ៤៥,៧ប៊ីលានដុល្លារ ខណៈដែលប្រាក់ បញ្ញើរបស់អតិថិជនបានកើនឡើងពី ១៥,៤%សមាមាត្រ ៣៨,៥ប៊ីលានដុល្លារ។

ស្របពេលជាមួយគ្នានេះដែរ,ធនាគារជាតិនៃកម្ពុជាបាន បញ្ជាក់ថា៖កំណើននេះត្រូវបានជំរុញដោយការកើនឡើង នៃតម្រូវការប្រាក់កម្ចីក្នុងពាណិជ្ជកម្ម លំនៅឋាន សំណង់ និងផលិតកម្ម ក្នុងចំណោមវិស័យផ្សេងទៀត។ ដោយ ឡែកសម្រាប់ ប្រាក់កម្ចីមិនដំណើរការ (NPL)ស្ថិតក្នុង អត្រាដែលអាចគ្រប់គ្រងបានគឺ ២,៤%។

នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជាបាន បង្ហាញថា សេដ្ឋកិច្ចរបស់កម្ពុជាបានស្ទុះងើបឡើងវិញក្នុង អត្រាប្រមាណ ៣%នៅឆ្នាំ ២០២១ បន្ទាប់ពីបានធ្លាក់ចុះ យ៉ាងខ្លាំង -៣,១ %ក្នុងឆ្នាំ ២០២០។ សម្រាប់ អតិផរណា របស់ប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍កាលពីឆ្នាំមុនមាន ចំនួន ២,៩% គឺជាអត្រាមួយដែលអាចគ្រប់គ្រងបានផង ដែរ។ការកើនឡើងនៃប្រាក់បញ្ញើអាចបង្ហាញយ៉ាងច្បាស់ ពីទំនុកចិត្តរបស់សាធារណៈជន និងអ្នកវិនិយោគក្នុង វិស័យធនាគារ។

បើទោះបីស្ថិតក្នុងបរិបទនៃការរីករាតត្បាតជំងឺកូវីដ-១៩, វិស័យធនាគារនៅតែមានស្ថិរភាពខ្លាំង ហើយបានចូលរួម ចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ការងើបឡើងវិញ នៃសេដ្ឋកិច្ច និងភាពធន់។ បច្ចុប្បន្ន ប្រទេសកម្ពុជាមាន ធនាគារពាណិជ្ជចំនួន ៥៦, ធនាគារឯកទេសចំនួន ១១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនទៀត ដែលមាន ការិយាល័យកណ្តាល និងសាខាសរុបចំនួន ២ ៦០០ ព្រម ទាំងម៉ាស៊ីនអេធីអឹមស្វ័យប្រវត្តិចំនួន ៣ ៥១២ នៅទូទាំង ប្រទេស។ ទន្ទឹមនឹងនេះក្នុងចំណោមប្រជាជនចំនួន ១៦ លាននាក់ មាន១២,១លាននាក់មានគណនីបញ្ញើ និង គណនីឥណទាន ៣,៣ លាននាក់នៅធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងប្រទេស៕ *ដោយ សេន ចន្នី*
*ប្រភព៖khmertimeskh,ចេញផ្សាយថ្ងៃទី១៧ខែមករា ឆ្នាំ២០២២*

## ចំណូលនាំចេញវាយនភណ្ឌជិត៩ពាន់លានដុល្លារ




*ដោយ Postkhmer*

អតីតប្រធានសមាគម(GMAC)បានឱ្យដឹងថា អត្រាកំណើននៃការនាំចេញប្រចាំឆ្នាំរបស់ GMAC មានលក្ខណៈគួរឱ្យសរសើរ លើកលែងតែរយៈពេលនៃវិបត្តិសកលធំៗ គឺវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨ និងវិបត្តិជំងឺរាតត្បាតឆ្នាំ ២០២០។ គោលនយោបាយល្អ និងសកម្មភាពរួមគ្នាប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋាភិបាល និងវិស័យឯកជនរបានវិលមករកភាពល្អប្រសើរក្នុងឆ្នាំ ២០២១ ដោយសារការគ្រប់គ្រងជំងឺរាតត្បាត និងកម្មវិធីចាក់វ៉ាក់សាំងប្រកបដោយប្រសិទ្ធភាព។ GMAC ក៏បានផ្តោតខ្លាំងផងដែរទៅលើការពង្រឹងសមត្ថភាពផ្ទៃក្នុងជាមួយនឹងច្បាប់ស្តីពីការវិនិយោគថ្មី បានផ្តល់ការលើកទឹកចិត្តច្រើនទៅដល់វិនិយោគិន និងការចាប់ផ្តើមអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ នាពេលខាងមុខ។

ប្រធានសមាគមរោងចក្រកម្ពុជាដែលទើបជ្រើសរើសសម្រាប់អាណត្តិថ្មី២០២២-២០២៣ បានបញ្ជាក់ដែរថា វិស័យកាត់ដេរបានឆ្លងកាត់នូវបញ្ហាប្រឈមរាប់មិនអស់ ក៏ប៉ុន្តែសមាគម និងសមាជិកទាំងអស់ បានរួមគ្នាពុះពារជម្នះរាល់ការលំបាករហូតទទួលបានជោគជ័យមកដល់បច្ចុប្បន្ននេះ។ កម្ពុជាបានចាប់ផ្តើមពីស្ថានភាពជាប្រទេសដែលមានការនាំចេញតិចតួច ហើយអភិវឌ្ឍខ្លួនក្លាយទៅជាប្រទេសចម្បងមួយដែលផ្គត់ផ្គង់ដល់ទីផ្សារពិភពលោក ដោយកំណើនប្រចាំឆ្នាំជាមធ្យមនៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះមានអត្រាប្រហែល ១០%។ ទោះបីមានការធ្លាក់ចុះបន្តិចបន្តួចនៅក្នុងឆ្នាំ ២០២០ ប៉ុន្តែយើងបានងើបឡើងវិញបានយ៉ាងលឿនក្នុងឆ្នាំ ២០២១ ដោយការនាំចេញក្នុងរយៈពេល ១០ ខែដំបូងមានកំណើនគួរឱ្យកត់សម្គាល់។ យើងបានប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើកិច្ចការពាក់ព័ន្ធទាំងឡាយ ពិសេសកិច្ចការជាអាទិភាពមួយចំនួនដូចជា បញ្ហាការងារ, ភ័ស្តុភារ,ពន្ធដារ,ការផ្គត់ផ្គង់វត្ថុធាតុដើម និងការបណ្តុះបណ្តាលធនធានមនុស្សបម្រើឱ្យវិស័យវាយនភណ្ឌ ក៏ដូចជាលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឧស្សាហកម្ម ៤.០។

បើតាមរដ្ឋមន្ត្រីក្រសួងការងារ ក្នុងឆ្នាំ ១៩៩៣ វិស័យវាយនភណ្ឌកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូបនៅកម្ពុជាមានរោងចក្រ សហគ្រាស និងកម្មករ មានតិចតួចប៉ុណ្ណោះ ប៉ុន្តែគិតត្រឹមនៅចុងឆ្នាំ ២០២១ រោងចក្រ សហគ្រាសដែលបានចុះបញ្ជីផ្លូវការក្នុងវិស័យនេះ បានកើនដល់ ១ ២០០ ដែលផ្តល់ការងារនៅក្នុងប្រព័ន្ធដល់កម្មករនិយោជិតប្រមាណជិត ១ លាននាក់។ ការនាំចេញនៅក្នុងវិស័យវាយនភណ្ឌ (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ) នារយៈពេល ១០ ខែនៃឆ្នាំ ២០២១ មានទឹកប្រាក់ ៨ ៨៣០ លានដុល្លារកើនជាង ១៣ % បើធៀបរយៈពេលដូចគ្នាឆ្នាំ ២០២០ ដែលមានតម្លៃប្រមាណ ៧ ៧៩៦ លានដុល្លារ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ postkhmer ចេញផ្សាយថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២។*

## ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ល្អបំផុតសម្រាប់ការចំណាយប្រតិបត្តិការផលិតកម្មទាបបំផុតក្នុងចំណោមប្រទេសចំនួនប្រាំបួននៅអាស៊ី



*ប្រភព៖khmertimeskh, 2021 រូបភាព៖ Pann Rachana*

យោងតាមក្រុមហ៊ុន TMX's ដែលជាទីប្រឹក្សាការផ្លាស់ប្តូរអាជីវកម្មឈានមុខគេនៅអាស៊ីប៉ាសីហ្វិកបានបង្ហាញថា ៖ ក្នុងចំណោមការចំណាយជាមធ្យមនៃការធ្វើធុរកិច្ចនៅអាស៊ី , ប្រទេសកម្ពុជាត្រូវបានគេរាយការណ៍ថាមានតម្លៃប្រតិបត្តិការទាបបំផុតក្នុងចំណោមប្រទេសចំនួន ៩ នៅអាស៊ី នាំមុខប្រទេសមីយ៉ាន់ម៉ា និងវៀតណាម។

តាមរយៈ TMX's បានវាយតម្លៃការចំណាយជាមធ្យមនៃការធ្វើអាជីវកម្មនៅអាស៊ី និងការប្រកួតប្រជែងរបស់ប្រទេសដែលត្រូវគ្នានៅទូទាំងទីតាំងផលិតកម្មដ៏ពេញនិយមចំនួន៩ដូចជា៖ កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

ការផ្លាស់ប្តូរខ្សែសង្វាក់ផ្គត់ផ្គង់ដ៏អស្ចារ្យ ការបំបែកតម្លៃនៃការធ្វើអាជីវកម្មនៅអាស៊ី ការចំណាយប្រតិបត្តិការសរុបជាមធ្យមសម្រាប់ក្រុមហ៊ុនផលិតនៅប្រទេសវៀតណាម មានចាប់ពី ៧៩ ២៨០ដុល្លារដល់ ២០៩ ០៨៧ ដុល្លារក្នុងមួយខែ បើប្រៀបធៀបទៅនឹងប្រទេសសិង្ហបុរីនាំមុខគេនៅ កម្រិត ៣៦៦ ៥៦១ ដុល្លារ និងចំណាត់ថ្នាក់លេខពីរប្រទេសថៃតម្លៃ ១៤២ ៣៤៤ ដុល្លារ។

សម្រាប់កម្លាំងពលកម្មមាន ៥៥%នៃការចំណាយសរុបនៅទូទាំងប្រទេស កម្ពុជា មីយ៉ាន់ម៉ា និងហ្វីលីពីន ដែលមានតម្លៃជាមធ្យម ១០៨ ១៩៦ ដុល្លារក្នុងមួយខែ ខណៈដែរ វៀតណាមជាប់ចំណាត់ថ្នាក់ទី៤ ដែលមានតម្លៃសមរម្យបំផុត។ បណ្តាប្រទេសដូចជាវៀតណាម ថៃ និងហ្វីលីពីន ផ្តល់កម្លាំងពលកម្មដែលមានទំហំធំ និងតម្លៃសមរម្យ។

តារាងពិន្ទុប្រកួតប្រជែង វៀតណាមជាប់ចំណាត់ថ្នាក់លេខ ៥ តាមពីក្រោយសិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌា និងថៃ។ ចំពោះការជួលឃ្លាំងដែលមានតម្លៃសមរម្យក្នុងចំណោមប្រទេសទាំងប្រាំបួនដែលជាកត្តាធំទីពីរនៃតម្លៃសរុបក្នុងចំណោមប្រទេសទាំង៩នោះ កម្ពុជាជាប់ចំណាត់ថ្នាក់លេខ៣តាមពីក្រោយប្រទេសថៃ និងមីយ៉ាន់ម៉ាតាមពីក្រោយដោយប្រទេសវៀតណាម៕ *ដោយ សេន ចន្ទី*

*ប្រភព៖khmertimeskh,ចេញផ្សាយថ្ងៃទី១៧ខែមករា ឆ្នាំ២០២២*

## តើទីផ្សារជ្រូកកម្ពុជាអាចរងឥទ្ធិពលជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅប្រទេសថៃ ដែរឬយ៉ាងណា?



*ដោយ ខេមបូណ្ឌមីស*

ប្រទេសថៃ បានប្រកាសពីការរកឃើញជំងឺប៉េស្តជ្រូកអាហ្វ្រិកលើកដំបូងនៅក្នុងប្រទេសរបស់ខ្លួន ស្របពេលកំពុងខ្វះសាច់ជ្រូកនៅលើទីផ្សារ និងបញ្ហាសាច់ជ្រូកឡើងថ្លៃ។ តាមពិតជំងឺប៉េស្តជ្រូកអាហ្វ្រិកមានវត្តមាននៅប្រទេសថៃ យូរមកហើយ ប៉ុន្តែ ថៃទើបប្រកាសជាផ្លូវការ។ កន្លងមក កម្ពុជា ក៏ធ្លាប់បានបង្ក្រាបករណីនាំចូលជ្រូកខុសច្បាប់ពីប្រទេសថៃមកកម្ពុជា ដែលមានផ្ទុកជំងឺប៉េស្តជ្រូកអាហ្វ្រិក កាលពីដើមឆ្នាំ២០២១ និងជំរុញឱ្យអគ្គនាយកដ្ឋានសត្វបានរឹតបន្តឹង និងតែងតែប្រុងប្រយ័ត្នខ្ពស់លើការនាំចូលជ្រូកពីប្រទេសថៃ។

ប្រធានសមាគមចិញ្ចឹមសត្វកម្ពុជាបានអះអាងដែរថា មិនមែនតែប្រទេសថៃ នោះទេដែលកំពុងផ្ទុះនូវជំងឺប៉េស្តជ្រូកអាហ្វ្រិក រួមទាំង ប្រទេសវៀតណាម ផងដែរ។ កម្ពុជា ស្ថិតនៅជាប់នឹងប្រទេសទាំងពីរ ដែលកំពុងមានបញ្ហារាតត្បាតជំងឺប៉េស្តជ្រូក សមាគមបានអំពាវនាវដល់ក្រុមអ្នកចិញ្ចឹមជ្រូកក្នុងស្រុក បង្កើនការប្រុងប្រយ័ត្ន។

មន្ត្រីជាន់ខ្ពស់ក្រសួងកសិកម្មកម្ពុជា បានអះអាងថា បញ្ហានេះ នឹងមិនបង្កឱ្យប៉ះពាល់ដល់ការចិញ្ចឹមជ្រូក ឬ ទីផ្សារសាច់ជ្រូករបស់កម្ពុជានោះទេ ដ្បិតថាបច្ចុប្បន្ន ប្រទេសថៃកំពុងខ្វះខាតសាច់ជ្រូក ដូច្នេះ ថៃមិនអាចនាំចេញជ្រូកមកកម្ពុជាទៀតនោះទេ។ កន្លងមកមានក្រុមហ៊ុនមួយចំនួនចង់នាំចូលសាច់ជ្រូកពីកម្ពុជាទៅថៃ ក៏ដូចជានាំសាច់ជ្រូកពីវៀតណាមឆ្លងកាត់កម្ពុជាដើម្បីទៅថៃដែរ តែវាពិតជាមានការលំបាកព្រោះប្រទេសថៃមិនមានទីតាំងសម្រាប់ធ្វើចត្តាឡីស័កសត្វ ក្នុងប្រទេសរបស់ខ្លួននោះទេ។ បច្ចុប្បន្ន យើងមានត្រឹមលទ្ធភាពផ្គត់ផ្គង់សាច់ជ្រូកលើទីផ្សារក្នុងស្រុកដោយខ្លួនឯង ប៉ុណ្ណោះ មិនទាន់មានលទ្ធភាពក្នុងការនាំចេញសាច់ជ្រូកទៅកាន់ទីផ្សារខាងក្រៅ។ ដើម្បីសម្រួលដល់ក្រុមចិញ្ចឹមជ្រូកក្នុងស្រុក កន្លងមក ក្រសួងកសិកម្ម បានផ្អាកទាំងស្រុងនូវការនាំចូលសត្វជ្រូករស់ពីបរទេស ដោយសារតែកម្ពុជា មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់សាច់ជ្រូក ដោយខ្លួនឯង។ បច្ចុប្បន្ន កម្ពុជា មានតម្រូវការជ្រូករស់ប្រមាណ ៨ពាន់ក្បាល ក្នុងមួយថ្ងៃនៅលើទីផ្សារក្នុងស្រុក ខណៈកម្ពុជា មានលទ្ធភាពផ្គត់ផ្គង់ជ្រូករស់ជិត ៨ពាន់ក្បាលក្នុងមួយថ្ងៃ។

បច្ចុប្បន្ននេះ នៅប្រទេសថៃ កំពុងជួបបញ្ហាខ្វះខាតសាច់ជ្រូក។ ការណ៍នេះ បានធ្វើឱ្យអាជីវករលក់សាច់ជ្រូកនៅប្រទេសថៃ បាននិងកំពុងអំពាវនាវឱ្យរដ្ឋាភិបាលចាប់ផ្តើមធ្វើការនាំចូលសាច់ជ្រូកពីក្រៅប្រទេសជាបន្ទាន់ ដើម្បីទប់ទល់នឹងការកើនឡើងថ្លៃសាច់ជ្រូកលើទីផ្សារ ខណៈដែលតម្លៃកើនឡើងខ្ពស់កំពុងធ្វើឱ្យបាត់បង់អ្នកទទួលទាន និងប្រាក់ចំណូលរបស់អ្នកលក់សាច់ជ្រូកផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១៣ខែមករាឆ្នាំ២០២២។*

## ការលើកលែងពន្ធលើមុខទំនិញមួយចំនួនពីរឆ្នាំជាការរួមចំណែកជួយរក្សាតម្លៃទំនិញលើទីផ្សារ



*ដោយ ខេមបូណូមីស*

វិបត្តិកូវីដ-១៩ កន្លងមកនេះ បានធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនធំជួបការលំបាកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ បន្ទាប់ពីប្រាក់ចំណូលរបស់ពួកគេធ្លាក់ចុះ ហើយទំនិញចាំបាច់មួយចំនួន ត្រូវបានជនឆ្លៀតឱកាសដំឡើងថ្លៃ។ ដើម្បីជួយសម្រួលជីវភាពរបស់ប្រជាពលរដ្ឋក្នុងអំឡុងនៃវិបត្តិនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចលើកលែងអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារចាំបាច់មួយចំនួន រួមមាន ទឹកត្រី ស្ករ អំបិល ទឹកស៊ីអ៊ីវ ត្រីទឹកសាប និងប្រៃ និងមុខទំនិញប្រភេទសាច់ និងស៊ុតចិញ្ចឹម។ ការលើកលែងអាករលើតម្លៃបន្ថែមនេះ មានរយៈពេលពីរឆ្នាំ ដោយអនុវត្តចាប់ពីថ្ងៃទី១ មករា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ធ្នូ ឆ្នាំ២០២៣។ យន្តការនេះ វានឹងជួយរួមចំណែករក្សាស្ថិរភាពតម្លៃទំនិញលើទីផ្សារមិនឱ្យឡើងថ្លៃខ្ពស់ និងជួយកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ។

អ្នកជំនាញសេដ្ឋកិច្ចនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ បានចាត់ទុកការដាក់ចេញយន្តការនេះ គឺជាគោលនយោបាយមួយដ៏សមស្របក្នុងបរិបទបច្ចុប្បន្ន ព្រោះជួយរក្សាស្ថិរភាពតម្លៃទំនិញលើទីផ្សារ ជួយកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ លើកកម្ពស់កម្រិតជីវភាពរស់នៅប្រជាពលរដ្ឋទូទៅ និងលើកកម្ពស់ប្រាក់ចំណូលរបស់ប្រតិបត្តិករ អាជីវករ ផងដែរ។ លោកជឿ

ដាក់ថា រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តដាក់ចេញវិធានការថ្មីៗបន្ថែមទៀត ដើម្បីជួយសម្រួលជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ការដាក់ចេញយន្តការរឿងសំខាន់មួយ តែអ្វីដែលកាន់តែសំខាន់ទៀតនោះ គឺរាជរដ្ឋាភិបាលគួរតាមដានការអនុវត្តវិធានការទាំងនោះឱ្យ ប្រកបដោយប្រសិទ្ធភាព។

កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយសម្រេចដាក់អាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារចាំបាច់របស់ពលរដ្ឋមួយចំនួនជាបន្ទុករបស់រដ្ឋ។ ប៉ុន្តែ មិនរាប់បញ្ចូលការផ្គត់ផ្គង់ម្ហូបអាហារដោយភោជនីយដ្ឋានទេ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២។*

## កម្ពុជាត្រូវវាយតម្លៃលើកដំបូងថាបានបំពេញលក្ខខណ្ឌចាំបាច់បី ដើម្បីរៀបចំចេញពីប្រទេសអភិវឌ្ឍតិចតួច




*ដោយ sbm.news*

នៅឆ្នាំ២០២១ កម្ពុជាត្រូវបានវាយតម្លៃជាលើកដំបូងដោយស្ថាប័នអង្គការសហប្រជាជាតិ ថា បានបំពេញបាននូវលក្ខខណ្ឌចាំបាច់បី ដើម្បីរៀបចំចាកចេញពីចំណាត់ក្រុមនៃប្រទេសអភិវឌ្ឍតិចតួច។លក្ខខណ្ឌចាំបាច់បី រួមមាន (១) ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ (GNI per Capita) ១ ៣៧៧ដុល្លារ ខ្ពស់ជាងលក្ខខណ្ឌកំណត់ដែលតម្រូវឱ្យមានតម្លៃទាបបំផុត ១ ២២២ដុល្លារ, (២) សន្ទស្សន៍ធនធានមនុស្ស (Human Assets Index - HAI) ៧៤,៣ពិន្ទុ ខ្ពស់ជាងលក្ខខណ្ឌកំណត់ដែលតម្រូវឱ្យមានពិន្ទុទាបបំផុត ៦៦ពិន្ទុ និង (៣) សន្ទស្សន៍ភាពងាយរងគ្រោះនៃសេដ្ឋកិច្ចនិងបរិស្ថាន (Economic and Environment Vulnerable Index) ៣០,៦ពិន្ទុ ទាបជាងលក្ខខណ្ឌកំណត់ដែលតម្រូវឱ្យមានពិន្ទុខ្ពស់បំផុត ៣២ពិន្ទុ។ ការបានបំពេញបាននូវលក្ខខណ្ឌចាំបាច់លើកទីមួយ ដើម្បីរៀបចំចាកចេញពីចំណាត់ក្រុមនៃប្រទេសអភិវឌ្ឍតិចតួចនេះ គឺជាការចាប់ផ្តើមនៃរបត់ប្រវត្តិសាស្ត្រថ្មីមួយរបស់កម្ពុជា ដែលបញ្ជាក់ពីផលនៃកិច្ចខិតខំប្រឹងប្រែងស្តារ និងកសាងប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជា និងការទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងនេះពីសហគមន៍អន្តរជាតិ។

ដំណើរការនៃការចាកចេញ តម្រូវឱ្យកម្ពុជាបំពេញបាននូវលក្ខខណ្ឌចាំបាច់ទាំងបីខាងលើម្តងទៀតជាលើកទីពីរនៅឆ្នាំ២០២៤។ ការចាកចេញនឹងត្រូវចូលជាធរមាននៅបីឆ្នាំបន្ទាប់ គឺនៅឆ្នាំ២០២៧។ ក្នុងអំឡុងពេលនេះ កម្ពុជាត្រូវមានយុទ្ធសាស្ត្រជាតិអំពី អន្តរកាលដោយរលូនមួយ (A National Smooth Transition Strategy) ដើម្បីធានាថា ការអភិវឌ្ឍប្រទេស នឹងមិនត្រូវបានរងការប៉ះពាល់ដោយសារការចាកចេញ។

លទ្ធផលនៃការវាយតម្លៃ នៃការបានបំពេញបាននូវលក្ខខណ្ឌចាំបាច់លើកទីមួយ នៅឆ្នាំ២០២១ខាងលើផ្អែកលើទិន្នន័យមុនវិបត្តិកូវីដ-១៩។ វិបត្តិកូវីដ-១៩ បានជះផលប៉ះពាល់អវិជ្ជមានដោយឥតព្រាងទុក ទៅលើវឌ្ឍនភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេស ទៅលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជា ទៅលើវិស័យដែលជាចន្ទល់នៃសេដ្ឋកិច្ច ដូចជា វិស័យទេសចរណ៍ និង វិស័យកម្មន្តសាលកាត់

ដែរ។ សេដ្ឋកិច្ចកម្ពុជាដែលធ្លាប់មានការរីកចម្រើនក្នុងអត្រាមួយថេរក្នុងរង្វង់ ៧%ក្នុងមួយឆ្នាំៗ បានជួបប្រទះនឹងកំណើនអវិជ្ជមាន (-៣,១%) នៅឆ្នាំ២០២០ ហើយអត្រាភាពក្រីក្រ ដែលយោងតាមវិធីសាស្ត្រគណនាថ្មី បានកើនឡើងដល់ ១៧,៨% ដោយសារការបាត់បង់ និងព្យួរការងារ នៅក្នុងវិស័យកម្មន្តសាលកាត់ដេរ និងវិស័យទេសចរណ៍។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ sbm.news ចេញផ្សាយថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ការប្រៀបធៀបអតិផរណា និងអត្រាប្តូរប្រាក់ក្នុងត្រីមាសទី៣ ឆ្នាំ២០២១

*រូបភាពទី១ ៖ សមាសភាគគណនីហិរញ្ញវត្ថុ*




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

រូបភាពទី១ ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបអតិផរណា និងអត្រាប្តូរប្រាក់រៀល ជាមួយប្រាក់ដុល្លារក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ អតិផរណាមធ្យមមានអត្រា ៣,២% ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២១ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ក្នុងនោះ សន្ទស្សន៍ថ្លៃប្រេងសាំងធម្មតា សាច់ជ្រូក និងត្រីបានកើនឡើង ៣២,៤%, ៤,៦%, ៤,១% រៀងគ្នា។ អតិផរណានេះក៏មានអត្រាខ្ពស់ជាងគេផងដែរ ក្នុងត្រីមាសដូចគ្នានៃឆ្នាំ ២០១៥ ដល់ ឆ្នាំ២០២០។ ទន្ទឹមនេះ អត្រាប្តូរប្រាក់មធ្យម ៤ ០៧៦,២ រៀល/ដុល្លារអាមេរិកបានធ្លាក់ចុះ ០,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ អត្រាប្តូរប្រាក់នេះ ក៏ធ្លាក់ចុះទាបជាងគេបំផុតផងដែរ ក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០១៥ ដល់ ឆ្នាំ២០២០៕

*ដោយ ឈន ហាំ*

*ប្រភព៖ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃកម្ពុជាចុះនាថ្ងៃទី១៥ធ្នូ ឆ្នាំ ២០២១*

### តារាងទី២៖ ការប្រៀបធៀបការវិនិយោគឯកជន ក្នុងត្រីមាសទី៣ ឆ្នាំ២០២១

*តារាងទី២៖ ស្ថិតិវិនិយោគវិស័យឯកជន(អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាវិនិយោគ | ឯកតា | ត្រីមាសទី៣ | | | កំណើន |
|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២១-២០ |
| គម្រោង សរុប | ចំនួន | 91 | 38 | 47 | 23.7% |
| បង្កើតការងារសរុប | ការងារ | 64,771 | 27,034 | 35,143 | 30.0% |
| ទុនវិនិយោគសរុប | លានដុល្លារ | 1,403 | 3,788 | 389 | -89.7% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)*

*សម្គាល់៖ វិនិយោគឯកជន៖ វិនិយោគជនក្នុងតំបន់សេដ្ឋកិច្ចពិសេស និងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស, ការអនុញ្ញាតវិនិយោគសរុប៖ រួមបញ្ចូល ការពង្រីកគម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស។*

តារាងទី២ ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបការវិនិយោគឯកជន ក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ គម្រោងវិនិយោគដែលបាន អនុម័តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) សរុបមានចំនួន ៤៧ គម្រោង បានកើនឡើង ៩ គម្រោង ស្មើនឹងជិត ២៤% ក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ ចំណែកឯ ទុនវិនិយោគសរុប មានចំនួន ៣៨៩ លានដុល្លារអាមេរិក បានធ្លាក់ចុះ ៩០%។ បង្កើតការងារសរុបមានចំនួន ៣៥ ១៤៣ កន្លែង បានកើនឡើង ៨ ១០៩ កន្លែង ស្មើនឹង ៣០% ធៀបនឹងរយៈពេល

ដូចគ្នាឆ្នាំ២០២០។ ទន្ទឹមនេះ គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលទាំងការពង្រីកគម្រោងសរុបទាំងអស់មានចំនួន៣៧គម្រោងបានកើនឡើង ៧ គម្រោងស្មើនឹង ២៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ដោយឡែក បើគិតជាទុនវិនិយោគមាន ទំហំសរុបចំនួនប្រមាណ ៣០៦ លានដុល្លារអាមេរិក បានធ្លាក់ចុះប្រហែល៩២% ដែលបណ្ដាលមកពីការធ្លាក់ ចុះខ្លាំង នៃការវិនិយោគលើផ្នែកសណ្ឋាគារ ថាមពល និងកសិដ្ឋានចិញ្ចឹមសត្វ៕ *ដោយ ឈន ហាំ*

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា ចុះនាថ្ងៃទី១៥ ធ្នូ ឆ្នាំ ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ឥណ្ឌូនេស៊ីព្រមបើកឱ្យមានការនាំចេញធ្យូងថ្មឡើងវិញ ហើយ ក្រោយផ្អាកអស់ជិតពីរសប្ដាហ៍



*ដោយ ខេមបូណ្ឌមីស*

ឥណ្ឌូនេស៊ី ដែលជាប្រទេសនាំចេញធ្យូងថ្មដ៏ធំមួយ បានប្រកាសផ្អាកការនាំចេញបណ្ដោះអាសន្នពេញមួយខែមករាឆ្នាំ២០២២ ព្រោះខ្លួនចង់ធានាការប្រើប្រាស់គ្រប់គ្រាន់នៅក្នុងស្រុក។ ប្រការនេះបានធ្វើឱ្យមានការបារម្ភខ្លាំង ពីប្រទេសធំៗដែលពឹងផ្អែកលើធ្យូងថ្មពីឥណ្ឌូនេស៊ី ដូចជាជប៉ុន កូរ៉េខាងត្បូង និងប្រទេសចិនជាដើម។ នៅទីបំផុត ប្រទេសឥណ្ឌូនេស៊ីបានសម្រេចចិត្តបើកឱ្យមានការនាំចេញធ្យូងថ្មឡើងវិញហើយ នៅថ្ងៃទី១៣មករានេះ។ ក្រោយពេលប្រកាសបើកការនាំចេញធ្យូងថ្មឡើងវិញភ្លាមមិនបានមួយថ្ងៃផង មាននាវាធំៗមិនតិចជាង១២០គ្រឿងឡើយ ដែលកំពុងរង់ចាំបន្តកន្ទុយគ្នា ត្រៀមដឹកជញ្ជូនធ្យូងថ្មចេញពីកំពង់ផែធ្យូងថ្ម នៃកោះ កាលីម៉ាន់តាន់ របស់ប្រទេសឥណ្ឌូនេស៊ី។ រដ្ឋាភិបាលឥណ្ឌូនេស៊ី បានដកបម្រាមចេញវិញនេះ គឺសម្រាប់ក្រុមហ៊ុនរុករកធ្យូងថ្មណា ដែលបានផលិតធ្យូងថ្មគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងស្រុក ហើយបានធានានូវប្រតិបត្តិការថាមពលក្នុងរយៈពេល១៥ថ្ងៃខាងមុខ។ រដ្ឋាភិបាល ក៏បានបន្ទោសក្រុមហ៊ុនសហព័ន្ធថាមពលឥណ្ឌូនេស៊ី ដែលជាក្រុមហ៊ុនរបស់រដ្ឋ ដែលមិនបានផ្គត់ផ្គង់ធ្យូងថ្មឱ្យគ្រប់តាមការកំណត់ ដែលបានធ្វើឱ្យមានការកាត់ផ្ដាច់ចរន្តអគ្គិសនីនៅក្នុងប្រទេសជាញឹកញាប់។ ការដែលមិនអាចសម្រេចទិន្នផលធ្យូងថ្ម តាមចំនួនកំណត់បានបែបនេះ ត្រូវបានក្រុមហ៊ុនអះអាងថា ដោយសារតែបញ្ហាអាកាសធាតុ និងកង្វះខាតគ្រឿងចក្រធំៗសម្រាប់រុករក។

គួរបញ្ជាក់ថា ការសម្រេចឱ្យមានការនាំចេញធ្យូងថ្មដូចធម្មតាឡើងវិញនេះ ធ្វើឡើងនៅបន្ទាប់ពី ប្រទេសជាច្រើនរួមទាំងប្រទេសជប៉ុន ហ្វីលីពីន និងកូរ៉េខាងត្បូង បានចេញមកទទូចឱ្យប្រទេសឥណ្ឌូនេស៊ី លុបចោលការហាមឃាត់ ដោយសារតែបារម្ភពីផលប៉ះពាល់ដល់តម្រូវការប្រើប្រាស់ថាមពលនៅតាមប្រទេសរៀងៗខ្លួន។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១៥ខែមករាឆ្នាំ២០២២។*

### រដ្ឋាភិបាលប្រទេសម៉ាឡេស៊ី ត្រៀមចំណាយថវិកាសរុប ៦៨០លានរីងហ្គីត ដើម្បីធានាស្ថិរភាពតម្លៃទំនិញចាំបាច់




*ប្រភព៖ CNA ២០២១, រូបភាព៖ AFP/Mohd Rasfan*

រដ្ឋាភិបាលម៉ាឡេស៊ីបានត្រៀមថវិកាសរុបចំនួន ៦៨០ លានរីងហ្គីត ស្មើនឹង ១៦២លានដុល្លារអាមេរិក ដើម្បីធានាបាននូវស្តង់ដារតម្លៃ និងស្ថិរភាពតម្លៃសម្រាប់ទំនិញចាំបាច់។ ក្នុងនោះទឹកប្រាក់សរុបចំនួន ៤០០ លានរីងហ្គីត ត្រូវបានត្រៀមសម្រាប់កម្មវិធីស្ថិរភាពតម្លៃប្រេងសម្រាប់ចម្អិនអាហារ និង ៤០លានរីងហ្គីត សម្រាប់កម្មវិធីឧបត្ថម្ភធនម្សៅសម្រាប់ការប្រើប្រាស់ទូទៅ ខណៈ ទឹកប្រាក់សរុបចំនួន ២៤០លានរីងហ្គីត ផ្សេងទៀត នឹងត្រៀមសម្រាប់ការអនុវត្តកម្មវិធីស្តង់ដារតម្លៃ ដែលរួមមាន៖ ការចំណាយសម្រាប់ស្ថិរភាពតម្លៃទំនិញចាំបាច់ តម្លៃហ្គាស (LPG) និងកម្មវិធីស្គរសហគមន៍ (Community Drumming Programme) នេះបើយោងតាមប្រសាសន៍របស់លោក Alexander Nanta Linggi រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្នុងស្រុក និងកិច្ចការអ្នកប្រើប្រាស់។

លោក Nanta Linggi បានបញ្ជាក់ថា តាមរយៈកម្មវិធីទាំងនេះ រដ្ឋាភិបាលក៏នឹងទទួលបន្ទុកលើការចំណាយថ្លៃដឹកជញ្ជូននូវទំនិញត្រួតពិនិត្យចំនួន ៧ ពីអ្នកផ្គត់ផ្គង់នៅក្នុងទីក្រុងទៅតំបន់ជនបទដែលបានកំណត់ ដែលការអនុវត្តកម្មវិធីនេះ អាចធានាថាទំនិញត្រូវបានលក់ក្នុងតម្លៃកំណត់ និងតម្លៃដូចគ្នានៅក្នុងទីក្រុងដែរ ព្រោះថ្លៃដឹកជញ្ជូនត្រូវបានចំណាយដោយរដ្ឋាភិបាល។ លោកបន្ថែមទៀតថា មានទីតាំងលក់ទំនិញទាំងអស់ចំនួន ២ ០០៥កន្លែង នៅទូទាំងប្រទេសដែលទំនិញចាំបាច់នឹងត្រូវដឹកជញ្ជូន កត់ត្រា និងលក់ទៅកាន់សហគមន៍មូលដ្ឋាន។

ដោយឡែក យោងតាមលោក Ameer Ali Mydin ម្ចាស់ហាងលក់ទំនិញរាយធំ Mydin បានឱ្យដឹងថា៖ តម្លៃទំនិញស្ងួត និងសម្លៀកបំពាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១០% ដោយសារចំណាយថ្លៃដើមខ្ពស់ដែលរោងចក្រផលិតប្រឈមមុខ និងគួបផ្សំនឹងបញ្ហាពាណិជ្ជកម្មអន្តរជាតិ។ លោករំពឹងថា តម្លៃទំនិញស្ងួត ដូចជា៖ នំ Biscuits ត្រីខកំប៉ុង និងភេសជ្ជៈម៉ាក Milo នឹងកើនឡើងក្នុងរង្វង់ពី ៨% ទៅ ១០% នៅឆ្នាំ២០២២ នេះ ដោយសារការកើនឡើងនៃតម្លៃវត្ថុធាតុដើម និងថ្លៃដឹកជញ្ជូន។ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ CNA ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២*

## ធនាគារជាតិឥណ្ឌូនេស៊ី នឹងរក្សាអត្រាការប្រាក់រហូតដល់ធមាសទី២ នៃឆ្នាំ២០២២ បើទោះបីជាធនាគារកណ្តាលអាមេរិក ដំឡើងអត្រាការប្រាក់ដើម្បីទប់ទល់នឹងការកើនឡើងអតិផរណាក៏ដោយ




*ប្រភព៖ CNA ២០២១, រូបភាព៖ REUTERS/Willy Kurniawan*

ធនាគារជាតិឥណ្ឌូនេស៊ី ត្រូវបានរំពឹងថានឹងរក្សាអត្រាការប្រាក់របស់ខ្លួននៅកម្រិតទាបក្នុងអត្រា ៣,៥% រហូតដល់ធមាសទី២ នៃឆ្នាំ២០២២ នៅក្នុងកិច្ចប្រជុំគោលនយោបាយដែលប្រព្រឹត្តឡើងនៅថ្ងៃទី ១៩-២០ ខែមករា ឆ្នាំ២០២២ សប្តាហ៍នេះ មុននឹងដំឡើងអត្រាការប្រាក់ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួន បើទោះបីជាធនាគារកណ្តាលអាមេរិក ទំនងជានឹងរឹតបន្តឹងនូវគោលនយោបាយរូបិយវត្ថុរបស់ខ្លួនក្នុងពេលឆាប់ៗខាងមុខ នៅក្នុងខែមីនា ឆ្នាំ២០២២ ក្តី នេះបើយោងតាមសេដ្ឋវិទូទាំង ៣០រូប ក្នុងការស្ទង់មតិរបស់ Reuters។ សេដ្ឋវិទូ ក៏បានកត់សម្គាល់ដែរថា «ខណៈពេលដែលធនាគារជាតិឥណ្ឌូនេស៊ី ប្រហែលជារក្សាអត្រាគោលនយោបាយស្ថិរភាពដើម្បីគាំទ្រសេដ្ឋកិច្ច ប៉ុន្តែ ធនាគារ

នៅតែអាចបង្ខំចិត្តដំឡើងអត្រាលឿនជាងអ្វីដែលសេដ្ឋវិទូបានសន្មត់ ប្រសិនបើការដំឡើងអត្រាការប្រាក់របស់ធនាគារកណ្ដាលអាមេរិកលឿនជាងការរំពឹងទុក ដែលនេះនឹងនាំឱ្យរូបបិយបណ្ណឥណ្ឌូនេស៊ីធ្លាក់ថ្លៃខ្លាំង»។
ការស្ទង់មតិ ក៏បានព្យាករណ៍ពីការកើនឡើងនៃអត្រាអតិផរណាផងដែរ ប៉ុន្តែស្ថិតនៅក្នុងកម្រិតគោលដៅរបស់ធនាគារជាតិឥណ្ឌូនេស៊ី ដែលជាមធ្យមក្នុងរង្វង់ ២,៩% និង ៣,១% សម្រាប់ឆ្នាំ ២០២២ និង ២០២៣ រៀងគ្នា។ ចំណែកឯ កំណើនផ.ស.ស. របស់ឥណ្ឌូនេស៊ីទំនងជានឹងកើនក្នុងអត្រា ៤,៧% នៅក្នុងត្រីមាសទី៤ នៃឆ្នាំ២០២១ និង ៣,៥% សម្រាប់ពេញមួយឆ្នាំ ២០២១ ខណៈ កំណើនពេញមួយឆ្នាំសម្រាប់ឆ្នាំ ២០២២ នេះ និងឆ្នាំ២០២៣ ត្រូវបានព្យាករណ៍ថានឹងមានកំណើន ៥,១%។
ជាមួយគ្នានេះ យោងតាមប្រសាសន៍របស់លោក Perry Warjiyo អគ្គទេសាភិបាលធនាគារជាតិឥណ្ឌូណេស៊ីៈ ការធ្វើឱ្យមានលក្ខណៈធម្មតានៃគោលនយោបាយ គឺមិនចាំបាច់ធ្វើតាមការផ្លាស់ប្ដូររបស់ធនាគារកណ្ដាលអាមេរិកទេ ហើយថាអត្រាការប្រាក់នឹងនៅតែទាបរហូតដល់អតិផរណាកើនឡើង។ នៅសហរដ្ឋអាមេរិក អត្រាអតិផរណាមានកម្រិតខ្ពស់ក្នុងរយៈពេល ៤០ឆ្នាំ ប៉ុន្តែអតិផរណានៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលជាប្រទេសសេដ្ឋកិច្ចធំបំផុតនៅអាស៊ីអាគ្នេយ៍ បានស្ថិតនៅក្រោមកម្រិតគោលដៅរបស់ធនាគារជាតិក្នុងរង្វង់ពី ២% ទៅ ៤% សម្រាប់រយៈពេល ១៩ខែ ដែលបានផ្ដល់លទ្ធភាពក្នុងការរក្សាអត្រាថេរ។ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ CNA ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២*

## ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេងរបស់សិង្ហបុរីទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែធ្នូ ឆ្នាំ ២០២១

តារាងខាងក្រោមបង្ហាញពី ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX: (Non-oil domestic exports)) ទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែធ្នូ ឆ្នាំ ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។
NODX ទៅកាន់ចិនបានកើនឡើង ៣៦,៣% នៅក្នុងខែធ្នូ ឆ្នាំ២០២១ ខណៈ NODX កាលពីខែមុនកើន ៤៥,៣%។ កំណើននេះជំរុញដោយឱសថបានកើនចំនួន ៧៣២,២% ម៉ាស៊ីនឯកទេសបានកើនចំនួន ៣៩,១% និងគីមីឥន្ទនៈ (petrochemicals) បានកើនចំនួន ១៨,៩%។
NODX ទៅកាន់ឥណ្ឌូនេស៊ីបានកើនឡើង ៦៦,១% នៅក្នុងខែធ្នូ ឆ្នាំ២០២១ បន្ទាប់ពីមានកំណើន ៣៣,៧%% កាលពីខែវិច្ឆិកា ឆ្នាំ២០២១។ កំណើននេះរួមចំណែកដោយមិនមែនរូបិយវត្ថុមាស (non-monetary gold) និងគីមីឥន្ទនៈ (petrochemicals) មានចំនួន ៨០,១% និងសារធាតុគីមីបឋម (primary chemicals) មានចំនួន ១០៤,៩%។
NODX ទៅកាន់សហគមន៍អឺរ៉ុបបានកើនឡើង ៣២,៥% នៅក្នុងខែធ្នូ ឆ្នាំ២០២១ បន្ទាប់ពីមានកំណើន ៨,៨% កាលពីខែមុន ឆ្នាំ២០២១។ ការកើនឡើងនេះ ដោយសារការនាំចេញម៉ាស៊ីនឯកទេសមានកំណើន ១០៧,៤% ឱសថមានកំណើន ២៩,៨% និងសារធាតុគីមីបឋម (primary chemicals) មានកំណើន ២៨៤,៨%។
ជារួម NODX ទៅកាន់ទីផ្សារធំៗទាំង១០ បានកើនឡើងនៅក្នុងខែធ្នូ ឆ្នាំ២០២១ ទោះបីជា NODX ទៅទីផ្សារអាមេរិក និងកូរ៉េខាងត្បូងបានធ្លាក់ចុះក៏ដោយ។ ទីផ្សារធំបំផុត នៃNODX របស់ប្រទេសសង្ហបុរី គឺចិនមាន ៣៦,៣% ឥណ្ឌូនេស៊ីមាន ៦៦,១% និងសហគមន៍អឺរ៉ុបមាន ៣២,៥%។ *ដោយ ជឹម ប៊ុនធឿន*

| ទីផ្សារធំៗ | កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (%) | |
|---|---|---|
| | វិច្ឆិកា ឆ្នាំ ២០២១ | ធ្នូ ឆ្នាំ២០២១ |
| ចិន | 45.3 | 36.3 |
| ឥណ្ឌូនេស៊ី | 33.7 | 66.1 |
| សហគមន៍អឺរ៉ុប | 8.8 | 32.5 |
| តៃវ៉ាន់ | 36.1 | 16.5 |
| ថៃ | -15.8 | 28.7 |
| ម៉ាឡេស៊ី | 14.4 | 13 |
| ជប៉ុន | 13.7 | 15.5 |
| ហុងកុង | 10.5 | 9.2 |
| កូរ៉េខាងត្បូង | 57.9 | -16.4 |
| អាមេរិក | 0.9 | -25.6 |

*ប្រភព៖www.enterprisesg.gov.sg*

## ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលខែចុងក្រោយ នៃខែវិច្ឆិកា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់ប្រទេសវៀតណាម មានចំនួន ១៧,២០ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន ១៥,៥៣ ពាន់លានដុល្លារ។ ដូច្នេះ ប្រទេសវៀតណាម មានអតិរេកពាណិជ្ជកម្មចំនួន ១,៦៧ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែចុងក្រោយ នៃខែវិច្ឆិកា ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែវិច្ឆិកា ឆ្នាំ ២០២១ ការនាំចេញរបស់វៀតណាមបានកើនឡើង ១៧,៨%។ កំណើននៃនាំចេញរួមចំណែកដោយ ទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់របស់វាបានកើន ២៨,១% ស្មើនឹង ៦៥៩ លានដុល្លារ កុំព្យូទ័រ ផលិតផលអេឡិចត្រូនិចបានកើន ២៨,៦% ស្មើនឹង ៥៨២ លានដុល្លារ ឧបករណ៍ម៉ាស៊ីន និងគ្រឿងបរិក្ខាបានកើន ១៩,6% ស្មើនឹង ៣៦៧ លានដុល្លា និងផលិតផលសម្លៀកបំពាក់បានកើន ៣០,៦% ស្មើនឹង ២០៩ លានដុល្លា។ ដោយឡែក ការនាំចូលបានកើនឡើង ៣,៧% ធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែវិច្ឆិកា ឆ្នាំ២០២១ ដែលឆ្លុះបញ្ចាំងពីការកើនឡើង នៃការនាំចូលទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់របស់វាមានចំនួន១៣,៩% ស្មើនឹង ១៥២ លានដុល្លារ កុំព្យូទ័រ និងផលិតផលអេឡិចត្រូនិចមានចំនួន ៣,២% ស្មើនឹង១២៣ លានដុល្លារ និងត្បូងថ្មមានចំនួន ៧៩,៦% ស្មើនឹង ១១៦ លានដុល្លារ។ *ដោយ ជីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៧,២០ |
| ការនាំចេញ | ១៥,៥៣ |
| អតិរេកពាណិជ្ជកម្ម | ១,៦៧ |

*ប្រភព៖ Vietnam Customs*

## ក្រុមហ៊ុនជប៉ុន៧០%នៅបន្ត និងពង្រីកធុរកិច្ចនៅមីយ៉ាន់ម៉ាក្រោយពេលមានរដ្ឋប្រហារយោធា



*ដោយ Postkhmer*

ទោះជាមានរដ្ឋប្រហារយោធា ទម្លាក់រដ្ឋាភិបាលស៊ីវិលកាលពីខែកុម្ភៈ ឆ្នាំ ២០២១កន្លងទៅក្តី ក៏ក្រុមហ៊ុនជប៉ុនប្រមាណ៧០%នៅតែបន្ត ឬពង្រីកធុរកិច្ចរបស់ខ្លួននៅក្នុងប្រទេសមីយ៉ាន់ម៉ាដដែល។

យោងតាមលទ្ធផលនៃការសម្រង់មតិ បានឱ្យដឹងថា ៥២,៣% នៃក្រុមហ៊ុនទាំងអស់នៅតែរក្សានូវទំហំនៃប្រតិបត្តិការរបស់ខ្លួនដដែល, ១៣,៥%បានធ្វើការពង្រីកមុខជំនួញរបស់ខ្លួន, ២៧,៥% បានកាត់បន្ថយជំនួញរបស់ខ្លួន ហើយ ៦,៧% បានធ្វើការដកខ្លួនចេញទាំងស្រុង ឬផ្លាស់ចេញទៅកាន់ប្រទេសទី៣។ ក្នុងរបាយការណ៍ចុះថ្ងៃទី ៩ ខែធ្នូ បានបន្ថែមថា ប្រសិនបើស្ថានភាពក្នុងស្រុកមីយ៉ាន់ម៉ាបន្តរ៉ាំរ៉ៃដូច្នេះ ក្រុមហ៊ុនជប៉ុនមួយចំនួន អាចនឹងគ្មានជម្រើសអ្វីក្រៅពីកាត់បន្ថយអាជីវកម្មរបស់ខ្លួន ឬដកខ្លួនចេញតែម្តង៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ postkhmer ចេញផ្សាយថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

### សន្ទស្សន៍ប្រេងឆៅពិភពលោក កើនឡើងដល់កម្រិតខ្ពស់ជាង ៧ឆ្នាំចុងក្រោយ



*ប្រភព៖ Mario Tama | Getty Images/ CNBC*

តម្លៃប្រេង បានកើនឡើងជាង ១ដុល្លារដល់កម្រិតខ្ពស់ជាង៧ឆ្នាំចុងក្រោយ ដោយសារការព្រួយបារម្ភអំពីការរំខានការផ្គត់ផ្គង់ដែលអាចកើតមានបន្ទាប់ពីក្រុមឧទាមហួតទីរបស់យេម៉ែន បានវាយប្រហារប្រទេសអារ៉ាប់រួមដោយបង្កើនអរិភាពរវាងក្រុមសម្ព័ន្ធមិត្តអ៊ីរ៉ង់ និងក្រុមចម្រុះដឹកនាំដោយអារ៉ាប៊ីសាអូឌីត។

អនាគតប្រេងឆៅរបស់ Brent បានកើនឡើង ៨៥ សេន ឬ ១% ដល់ ៨៧.៣៣ ដុល្លារក្នុងមួយបារ៉ែល បន្ទាប់ពីបានឡើងដល់កំពូល៨៧.៥៥ដុល្លារ ដែលជាតម្លៃខ្ពស់បំផុតចាប់តាំងពីថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០១៤។ ខណៈពេលដែលប្រេងឆៅនាពេលអនាគតរបស់អាមេរិក West Texas Intermediate (WTI) បាន កើនឡើង ១.១៣ ដុល្លារ ឬ ១.៤% ពីការទូទាត់កាលពីថ្ងៃសុក្រដល់កម្រិតខ្ពស់ជាងពីរខែគឺ ៨៤.៩៥ ដុល្លារក្នុងមួយធុង។

ជាមួយគ្នានេះ តម្លៃប្រេង ក៏ត្រូវបានកើនឡើងដោយសារសីតុណ្ហភាពរដូវរងាកាន់តែត្រជាក់នៅអឌ្ឍគោលខាងជើង ដែលកំពុងជំរុញឱ្យមានតម្រូវការសម្រាប់ប្រេងឥន្ធនៈកំដៅ ខណៈពេលដែលពិភពលោកចាប់ផ្តើមដំណើរការទៅតាមគន្លងធម្មតានៃតម្រូវការប្រេងឡើងវិញ បន្ទាប់ពីការបិទខ្ទប់រយៈពេល២ឆ្នាំ ដែលធ្វើអោយតម្រូវការនឹងលើសពីការផ្គត់ផ្គង់នៅឆ្នាំនេះ។

ម្យ៉ាងវិញទៀត អ្នកផលិតមួយចំនួននៅក្នុងអង្គការនៃប្រទេសនាំចេញប្រេង(OPEC) កំពុងជួបការលំបាកក្នុងការបូមប្រេងតាមសមត្ថភាពដែលអនុញ្ញាតរបស់ពួកគេ ដោយសារតែការវិនិយោគតិច និងការដាច់ភ្លើងក្រោមកិច្ចព្រមព្រៀងជាមួយរុស្ស៊ី និងសម្ព័ន្ធមិត្តដែលហៅថា OPEC+ ដើម្បីបន្ថែមចំនួនផលិត ៤០០ ០០០ បារ៉ែលក្នុងមួយថ្ងៃរៀងរាល់ខែ។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី១៨ ខែមករាឆ្នាំ២០២១*

### សេដ្ឋកិច្ចចិនកើនឡើង៨.១%ក្នុងឆ្នាំ២០២១



*ប្រភព៖ Yin Liqin | China News Service | Getty Images*

សេដ្ឋកិច្ចរបស់ប្រទេសចិន បានកើនឡើង៨.១% ក្នុងឆ្នាំ២០២១ ដោយសារផលិតកម្មឧស្សាហកម្មបានកើន

ឡើងជាលំដាប់រហូតដល់ដំណាច់ឆ្នាំ និងផាត់ទាត់ការធ្លាក់ចុះនៃការលក់រាយ យោងតាមទិន្នន័យផ្លូវការពីការិយាល័យស្ថិតិជាតិរបស់ប្រទេសចិន។

GDP ត្រីមាសទី៤ បានកើនឡើង៤% ធៀបនឹងឆ្នាំមុន ដែលលឿនជាងការព្យាករណ៍កើនឡើង ៣.៦% ដោយការស្ទង់មតិរបស់ Reuters ។ សម្រាប់រយៈពេលពេញមួយឆ្នាំ អ្នកសេដ្ឋកិច្ចចិន រំពឹងថានឹងមានកំណើនជាមធ្យម ៨.៤% ក្នុងឆ្នាំ២០២១ នេះបើយោងតាមអ្នកផ្តល់ទិន្នន័យហិរញ្ញវត្ថុ Wind Information។

ផលិតកម្មឧស្សាហកម្ម បានកើនឡើង ៤.៣% នៅក្នុងខែធ្នូ ធៀបនឹងឆ្នាំមុន ដែលលើសពីការព្យាករណ៍របស់ Reuters នៃកំណើន ៣.៦% ។ គួរកត់សម្គាល់ថា ការផលិតរថយន្ត បានកើនឡើងជាលើកដំបូងចាប់តាំងពីខែមេសា កើនឡើង ៣.៤% ធៀបនឹងឆ្នាំមុននៅក្នុងខែធ្នូ។

ការវិនិយោគទ្រព្យសកម្មសម្រាប់ឆ្នាំ ២០២១ បានកើនឡើង ៤.៩% លើសពីការរំពឹងទុកសម្រាប់កំណើន៤.៨% ។ ការវិនិយោគលើអចលនទ្រព្យ បានកើនឡើង ៤.៤% ខណៈដែលហេដ្ឋារចនាសម្ព័ន្ធកើនឡើង ០.៤%។

ការវិនិយោគក្នុងវិស័យកម្មន្តសាល បានកើនឡើង ១៣.៥% ក្នុងឆ្នាំ ២០២១ ធៀបនឹងឆ្នាំមុន ជាមួយនឹងការកើនឡើងនៃគ្រឿងចក្រ ២៤.៣% ប្រចាំឆ្នាំ។

ទោះជាយ៉ាងណា ការលក់រាយ បានខុសការរំពឹងទុក ដែលបានកើនឡើងត្រឹម១.៧% នៅក្នុងខែធ្នូ ធៀបនឹងឆ្នាំមុន ខណៈដែលអ្នកវិភាគដែលត្រូវបានស្ទង់មតិដោយ Reuters បានព្យាករណ៍ថានឹងមានការកើនឡើងទៅដល់ ៣.៧% ។ *ដោយ វត្ថា វង្សខ្មែរៈ*

*ប្រភព៖គេហទំព័រសារព័ត៌មានCNBCចុះថ្ងៃទី១៦ខែមករាឆ្នាំ២០២១*

## ការដោះដូរពាណិជ្ជកម្មចិនជាមួយនឹងប្រទេសជាដៃគូសំខាន់ៗនៅឆ្នាំ២០២១



*ដោយ ខេមបូណ្ណមីស*

ឆ្នាំ២០២១ជាខួបទី២០ឆ្នាំរបស់ប្រទេសចិន ដែលបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ២០ឆ្នាំកន្លងមកនេះ ចិនបានប្រមូលយកបទពិសោធន៍ជាច្រើនក្នុងការបើកចំហសេដ្ឋកិច្ច និងសម្រេចបានលទ្ធផលល្អ។ ពេញមួយឆ្នាំ២០២១ ទំហំនៃនៃការដោះដូរទំនិញរបស់ចិនមានជាង៦ទ្រីលានដុល្លារអាមេរិក កើនឡើងជាង២០%បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ នេះជាលើកទីមួយហើយសម្រាប់ប្រទេសចិន ដែលសម្រេចបានទំហំដោះដូរពាណិជ្ជកម្មសរុបចំនួន ៦ ទ្រីលានដុល្លារអាមេរិក ដែលជាកំណត់ត្រាថ្មីនៅក្នុងរយៈប៉ុន្មានជាច្រើនឆ្នាំកន្លងមកនេះ។ ក្នុងអំឡុងវិបិត្តកូវីដ-១៩ចិនបានយកដៃម្ខាងទប់ទល់នឹងរោគរាតត្បាត និងដៃម្ខាងខំថែរក្សាខ្សែសង្វាក់ឧស្សាហកម្ម និងការផ្គត់ផ្គង់ជាសកល។ ចិននៅតែរក្សាបាននូវភាពធន់នៃពាណិជ្ជកម្មរបស់ខ្លួន ទោះបានឆ្លងកាត់បញ្ហាធំៗជាច្រើននៅពេញមួយឆ្នាំហើយក្តី។ ភាពធន់នេះ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះស្ថិរភាព និងការធ្វើឱ្យប្រសើរឡើងនៃសេដ្ឋកិច្ចចិន។

តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យពាណិជ្ជកម្មរបស់ចិនមានភាពធន់ដូចនេះ?

### ១.តាមរយៈគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ

ចិនមានដៃគូពាណិជ្ជកម្មធំៗចំនួន៥ រួមមាន ប្រទេសតំបន់អាស៊ាន សហភាពអឺរ៉ុប សហរដ្ឋអាមេរិក ជប៉ុន និងប្រទេសកូរ៉េខាងត្បូង។ ដោយលើកលែងប្រទេស

ដប៉ុនមួយចេញ ការដោះដូរពាណិជ្ជកម្មរវាង ចិននិងប្រទេសទាំង៤ខាងលើ នៅឆ្នាំ២០២១ សុទ្ធសឹងតែសម្រេចបាននូវកំណើន២ខ្ទង់ បើធៀបនឹងឆ្នាំ២០២០។ ក្រៅពីតែកំណើនជាមួយដៃគូធំៗ ពាណិជ្ជកម្មរបស់ប្រទេសចិនជាមួយប្រទេសកំពុងមានទីផ្សារីកចម្រើន ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ជាក់ស្តែង នៅពេញមួយឆ្នាំ ២០២១ទំហំពាណិជ្ជកម្មសរុបជាមួយប្រទេសហត្ថលេខី នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវបានកើនដល់ជិត ២ ទ្រីលានដុល្លារអាមេរិក កើនឡើងជិត ២៤%។ គិតមកដល់បច្ចុប្បន្ន ប្រទេសចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំនួន ៧ ជាមួយប្រទេសចំនួន ១៣ នៅក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវរួចហើយ រួមទាំងកម្ពុជាយើងក៏មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយចិនដែរ។ លើសពីនេះទៀត ក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវដដែល ពាណិជ្ជកម្មរវាងចិន និងប្រទេសមួយចំនួននៅតំបន់អឺរ៉ុប តាមរយៈផ្លូវរថភ្លើងក៏បានកើនឡើងយ៉ាងឆាប់រហ័សដូចគ្នាដែរ។ នៅពេញមួយឆ្នាំ ២០២១ រថភ្លើងដឹកទំនិញ១ម៉ឺន៥ពាន់ទូរ ស្មើនឹងទូរកុងតឺន័រជាង១លាន៥សែន ត្រូវបាននាំចេញពីប្រទេសចិនទៅកាន់ប្រទេសតំបន់អឺរ៉ុប ដោយចំនួននេះបានកើនឡើងជិត ៣០%។

**២.ជាមួយសមាជិកនៃកិច្ចព្រមព្រៀង RCEP**

អាស៊ានបានក្លាយជាដៃគូពាណិជ្ជកម្មធំជាងគេបំផុត របស់ចិន សម្រាប់រយៈពេលពីរឆ្នាំជាប់ៗគ្នា ពោលគឺឆ្នាំ២០២០និងឆ្នាំ២០២១។ ជាក់ស្តែង ពាណិជ្ជកម្មអាស៊ានចិន រក្សាបានកំណើនល្អក្នុងទំហំជិត១ទ្រីលានដុល្លារអាមេរិក កើនឡើងជិត២០%។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី RCEP បានចូលជាធរមានចាប់ពីថ្ងៃទី០១ខែមករាមក សម្រាប់ប្រទេស១០ ក្នុងចំណោមសមាជិកទាំង១៥។ ចាប់ពីពេលនោះមក អត្រាពន្ធសូន្យភាគរយរវាងពាណិជ្ជកម្មចិន អាស៊ាន អូស្ត្រាលី និងញូហ្សេលែន បានគ្របដណ្តប់លើសពី ៦៥%នៃពាណិជ្ជកម្មសរុប ហើយក្នុងនោះគោលដៅរបស់ RCEP គឺសម្រេចឲ្យបាននូវពន្ធសូន្យលើការជួញដូរទំនិញជាង ៩០% ក្នុងចំណោមរដ្ឋជាសមាជិកទាំងអស់នាពេលអនាគត៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។*

## អតិផរណាអាមេរិក កើនខ្ពស់ដល់កម្រិតមិនធ្លាប់មានក្នុង ៤០ឆ្នាំចុងក្រោយនេះ



*ដោយ ខេមបូណ្ឌមីស*

នៅសហរដ្ឋអាមេរិក អត្រាកំណើនអតិផរណាទូទៅបានកើនឡើងខ្លាំងគឺ ៧% កាលពីខែធ្នូឆ្នាំមុន ធ្វើឱ្យការចំណាយរបស់ក្រុមគ្រួសារកើនឡើង ប៉ះពាល់ដល់ប្រាក់ចំណូលពួកគាត់។ តម្លៃប្រេង ហ្គាស អាហារ និងសម្ភារៈផ្សេងៗបានឡើងថ្លៃដោយសារការស្ទុះងើបឡើងវិញយ៉ាងលឿននៃសេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២១ ក្រោយកូវីដ១៩បានធូរស្បើយបន្តិច ព្រោះមនុស្សចាប់ផ្តើមមានតម្រូវការឡើងវិញ រីឯការផ្គត់ផ្គង់មិនទាន់តម្រូវការ។ បន្ថែមពីលើនេះ ការទម្លាក់កញ្ចប់ថវិកាជំនួយ និងកម្ចីដែលមានអត្រាការប្រាក់ទាបខ្លាំងពីរដ្ឋាភិបាលអាមេរិក បានជួយជំរុញតម្រូវការប្រើប្រាស់កើនឡើង ខណៈយុទ្ធនាការចាក់វ៉ាក់សាំង បានបង្កើនទំនុកចិត្តរបស់ពលរដ្ឋឱ្យចេញដើរហើរ និងទទួលទានអាហារនៅខាងក្រៅ។ ក្នុងពលរដ្ឋអាមេរិកកំពុងសម្រុកចាយ

លុយនោះ ខ្សែសង្វាក់ផ្គត់ផ្គង់ខ្លះនៅជាប់គាំងនៅឡើយ ដោយសារតែកង្វះខាតកម្មករ និងវត្ថុធាតុដើម ជាហេតុបានដាក់សម្ពាធទៅលើតម្លៃរបស់ទំនិញឱ្យកើនឡើងមួយកម្រិតទៀត។ តម្លៃទំនិញមិនរាប់បញ្ចូលប្រេងឥន្ធនៈ និងអាហារ បានកើនឡើង ៥,៥%ទៀតកាលពីខែធ្នូ ខណៈអត្រាអតិផរណាទូទៅកើនដល់៧% ដែលជាអត្រាខ្ពស់បំផុតមិនធ្លាប់មានក្នុង៤ទសវត្សចុងក្រោយ។ អតិផរណានៅអាមេរិកបន្តកើនឡើងឥតឈប់ឈរ បង្កជាសម្ពាធមួយ ដែលត្រូវចាំបាច់ដោះស្រាយឱ្យបានឆាប់រហ័ស។ អ្នកជំនាញសេដ្ឋកិច្ចនៅអាមេរិក អះអាងថា អតិផរណានេះ នឹងមិនស្រុតចុះក្នុងពេលឆាប់ៗនេះឡើយ។ នៅតែបង្ហាញភាពជឿជាក់ថា អតិផរណានៅអាមេរិកនឹងធ្លាក់ចុះមកវិញ ដរាបណារោងចក្រ និងសហគ្រាសធំៗ ពិសេសអ្នកផលិតចំណីអាហារ ឈប់ឆ្លៀតឱកាសដំឡើងថ្លៃដើម្បីប្រាក់ចំណេញ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១៥ខែមករា ឆ្នាំ២០២២។*

## ការប្រែប្រួលសេដ្ឋកិច្ចសកល និងប្រទេសកំពុងអភិវឌ្ឍន៍នៅឆ្នាំ២០២២



*ដោយ ខេមបូណូមីស*

ធនាគារពិភពលោកបានព្យាករចុងក្រោយចំពោះកំណើនសេដ្ឋកិច្ចសកលលោកនៅឆ្នាំ២០២២ថា នឹងមានកំណើនយឺតត្រឹម៤,១%ប៉ុណ្ណោះ ដែលកាលពីឆ្នាំ២០២១កើន ៥,៥%។ នៅឆ្នាំ២០២៣ កំណើនសេដ្ឋកិច្ចពិភពលោកនឹងបន្តថមថយថែមទៀតមកនៅត្រឹម ៣,២% ដោយសារតែតម្រូវការធ្លាក់ចុះ។ សម្រាប់ការព្យាករពីស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ ចំពោះកំណើនសេដ្ឋកិច្ចពិភពលោកវិញ ក៏ត្រូវបានគេរំពឹងថានឹងមានទាបជាងមុនដែរ។

បើមើលទៅលើរបាយការណ៍ពីធនាគារពិភពលោកបង្ហាញថា សម្រាប់ឆ្នាំ២០២១ សកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ គឺមានការស្ទុះងើបឡើងខ្លាំង។ ប៉ុន្តែក៏ព្រមានផងដែរ អំពីការកើនឡើងកម្រិតអតិផរណាក្នុងរយៈពេលវែង បញ្ហាទាក់ទងនឹងខ្សែចង្វាក់ផ្គង់ផ្គង់ និងកម្លាំងពលកម្ម និងការរាតត្បាតនៃមេរោគបំប្លែងថ្មីៗ ដែលកត្តាធ្វើឱ្យកំណើនសេដ្ឋកិច្ចនៅទូទាំងពិភពលោកនឹងមានការធ្លាក់ចុះ។ ប្រទេសកំពុងអភិវឌ្ឍន៍កំពុងប្រឈមបញ្ហាធ្ងន់ធ្ងររយៈពេលវែង ទាក់ទងនឹងអត្រានៃការចាក់វ៉ាក់សាំងមានក្នុងកម្រិតទាប បញ្ហាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសកល និងបន្ទុកបំណុលជាដើម។ តាមការព្យាករ កំណើនរបស់ប្រទេសមានសេដ្ឋកិច្ចជឿនលឿននឹងមានត្រឹម ៣,៨% នៅឆ្នាំ២០២២ ថមថយពី៥% កាលពីឆ្នាំ២០២១ ខណៈនៅឆ្នាំ២០២៣ នឹងរក្សាបានកំណើន ២,៣%។ សម្រាប់សេដ្ឋកិច្ចអាមេរិកវិញនៅឆ្នាំ ២០២១ ត្រូវបានប៉ាន់ប្រមាណថាកើន ៥,៦% ហើយកំណើននេះនឹងថមថយមកនៅត្រឹម៣,៧%នៅក្នុងឆ្នាំ ២០២២។ រីឯ សេដ្ឋកិច្ចជប៉ុនវិញ នៅឆ្នាំ២០២១ មានកំណើន១,៧% និងបន្តកើនដល់២,៩% នៅឆ្នាំ ២០២២។ ចំពោះសេដ្ឋកិច្ចមហាយក្សចិនឯណោះវិញនឹងកើនដល់៨% នៅឆ្នាំ២០២១ ហើយឆ្នាំ២០២២នឹងកើនយឺតមកនៅត្រឹម ៥,១% និងឆ្នាំ២០២៣ កើន ៥,៣%។

គិតមកទល់បច្ចុប្បន្ន សម្រាប់អ្នកដែលបានចាក់វ៉ាក់សាំងវិញនៅទូទាំងពិភពលោកទើបមានប្រមាណ ៦០%ប៉ុណ្ណោះ ដែលទទួលបានការចាក់វ៉ាក់សាំងយ៉ាង

ហោចណាស់១ដូស ខណៈប្រទេសចំណូលទាប និងមធ្យមវិញ មានប្រមាណតែ៩%ប៉ុណ្ណោះ ដែលបានចាក់វ៉ាក់សាំងបាន១ដូស៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២។*

## ប្រធានធនាគារពិភពលោកប្រាប់ឱ្យប្រទេសចិន ជួយបន្ធូរបន្ថយបំណុលសម្រាប់ប្រទេសក្រីក្រ




*ដោយ ខេមបូណូមីស*

មានប្រទេសជាច្រើនឥឡូវនេះកំពុងប្រឈមនឹងកម្រិតបំណុលខ្ពស់រួមទាំងបំណុលក្នុងស្រុក និងខ្ចីពីបរទេស ដោយសារតែអត្រាការប្រាក់ចាប់ផ្តើមកើនឡើងកាន់តែខ្ពស់។ នៅក្នុងនោះ មានប្រហែល ៦០%នៃប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម ដែលស្ថិតនៅក្នុងហានិភ័យបំណុលកម្រិតខ្ពស់។ ចំពោះប្រទេសមានទីផ្សារកំពុងរីកចម្រើនវិញ ក៏កំពុងស្ថិតនៅក្នុងបញ្ហាជំពាក់បំណុលនេះដូចគ្នាដែរ។ នៅពេញ១ឆ្នាំ២០២២ នេះ ប្រទេសនានាដែលជំពាក់បំណុល គឺនឹងត្រូវបង់សង៣៥ពាន់លានដុល្លារ ទៅកាន់ប្រទេសម្ចាស់ក្នុងក្របខ័ណ្ឌទ្វេភាគី និងម្ចាស់បំណុលជាវិស័យឯកជនជាដើម ហើយក្នុងនោះ គឺមានប្រហែល៤០% ជាបំណុលដែលជំពាក់ប្រទេសចិន។

ប្រធានធនាគារពិភពលោកបានស្នើឱ្យប្រទេសចិន ដែលជាម្ចាស់បំណុលដ៏ធំរបស់ប្រទេសក្រីក្រជាច្រើន នៅលើពិភពលោក ជួយបន្ធូរបន្ថយបំណុលសម្រាប់ប្រទេសក្រីក្រដែលបានជំពាក់។ ហើយម្ចាស់បំណុលដែលជា វិស័យឯកជន ឬម្ចាស់បំណុលបែបពាណិជ្ជកម្ម ក៏ត្រូវជួយសម្រាលបន្ទុកបំណុលនេះ ដូចគ្នាដែរ។ ធនាគារពិភពលោក ក៏បានអំពាវនាវឱ្យមានការពន្លឿនការបន្តអនុវត្តនូវក្របខ័ណ្ឌរួម សម្រាប់ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ ដែលត្រូវបានយល់ព្រមរួចហើយ ដោយក្រុមប្រទេសសេដ្ឋកិច្ចរីកចម្រើនទាំង២០ ឬហៅថា G20 រួមទាំងប្រទេសចិនផងដែរ កាលពីខែវិច្ឆិកាឆ្នាំ២០២០កន្លងទៅ។ តាមរយៈក្របខ័ណ្ឌរួមសម្រាប់ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញនោះ នឹងមានការផ្តល់ជូននូវការបន្ធូរបន្ថយបំណុល ឬអាចមានដល់ការលុបចោលបំណុលផងដែរ សម្រាប់ប្រទេសដែលបានស្នើសុំ។ ក្របខ័ណ្ឌរួមនេះ ត្រូវបានក្រុមប្រទេស G20 បង្កើតឡើង នៅពេលមានការចាប់ផ្តើមផ្ទុះរាលដាលកូវីដ១៩ ដើម្បីជួយដល់ប្រទេសក្រីក្រផ្អាកការទូទាត់សេវាបំណុលនៅចុងឆ្នាំ២០២០ ហើយវាក៏ត្រូវបានបន្ត រហូតដល់ចុងឆ្នាំ២០២១ផងដែរ។

ថ្មីៗនេះ ប្រធានាធិបតីប្រទេសស្រីលង្កា ក៏ទើបតែបានស្នើដល់ប្រទេសចិន ជួយសម្រួលដល់លក្ខខណ្ឌសងបំណុលផងដែរ ដ្បិតប្រទេសនេះកំពុងជួបបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរ។ ទោះយ៉ាងណាក៏ដោយ ភាគីចិន នៅមិនទាន់មានការសម្រេចបែបណាចំពោះការស្នើសុំរបស់ប្រទេសស្រីលង្ការនេះទេ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៤ ខែមករា ឆ្នាំ២០២២

- អត្រាអតិផរណាពាក់កណ្តាលខែនៅប្រទេសម៉ិកស៊ិកបានកើនឡើងដល់ 7.45%នៅក្នុងខែធ្នូ ពី 7.05% នៅក្នុងខែវិច្ឆិកា 2021
- អត្រាអតិផរណាប្រចាំឆ្នាំនៅក្នុងប្រទេសអូស្រ្តាលី បានធ្លាក់ចុះមកត្រឹម 3.0% នៅក្នុង Q3 2021

ថ្ងៃអង្គារ ទី២៥ ខែមករា ឆ្នាំ២០២២

- GDP ប្រចាំខែនៅក្នុងប្រទេសម៉ិកស៊ិកបានកើនឡើងដល់ -0.20% នៅក្នុងខែតុលាពី -0.40 % នៅក្នុងខែកញ្ញាឆ្នាំ 2021
- តម្លៃអ្នកប្រើប្រាស់របស់ប្រទេសអូស្ត្រាលីបានកើនឡើង 0.8% នៅក្នុងត្រីមាសទី 3 ឆ្នាំ 2021 ដែលជាល្បឿនដូចគ្នាទៅនឹងរយៈពេលមុន និងស្របតាមការរំពឹងទុករបស់ទីផ្សារ

ថ្ងៃពុធ ទី២៦ ខែមករា ឆ្នាំ២០២២

- ប្រាក់ចំណូលរបស់រដ្ឋាភិបាលនៅក្នុងប្រទេសប្រេស៊ីលបានថយចុះ នៅក្នុងខែវិច្ឆិកា ធៀបនឹងខែតុលាឆ្នាំ 2021
- ឱនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកបានកើនឡើងដល់កម្រិតខ្ពស់បំផុត ក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី២៧ ខែមករា ឆ្នាំ២០២២

- តម្លៃនាំចូលរបស់អូស្ត្រាលីបានកើនឡើងនៅត្រីមាសទី៣ 2021
- ធនាគារកណ្តាលនៃប្រទេសទួរគី បានកាត់បន្ថយអត្រាការជេញថ្លៃឡើងវិញក្នុងរយៈពេលមួយសប្តាហ៍ ក្នុងអំឡុងពេលកិច្ចប្រជុំខែធ្នូរបស់ខ្លួន

ថ្ងៃសុក្រ ទី២៨ ខែមករា ឆ្នាំ២០២២

- កំណើនសេដ្ឋកិច្ចរបស់ប្រទេសបារាំង ត្រូវបានបញ្ជាក់ក្នុងអត្រា 3%ក្នុងរយៈពេលបីខែដល់ខែកញ្ញាឆ្នាំ 2021
- អត្រានីកម្មភាពរបស់ប្រទេសប្រេស៊ីលបានធ្លាក់ចុះមកត្រឹម 12.1% ខែតុលា ឆ្នាំ 2021។